គម្រោងគាំទ្រសេវាអប់រំកុមារនៅតំបន់ដាច់ស្រយាល

***Educational Support to Children in Underserved Populations (ESCUP)***

# វិធីសាស្ត្របង្កើតក្លឹបអ្នកនិពន្ធ

# សម្រាប់

# សាលាមធ្យមសិក្សា


**កំពង់ចាម, ខែ កក្កដា ២០០៦**

**ឆ្នាំសិក្សា ២០០៦-០៧**

# ការបង្កើតក្លឹបនិពន្ធ

## ១ . សេចក្តីផ្តើម

មេរៀននេះរៀបចំឡើងសម្រាប់ជួសសិស្សនៅសាលាមធ្យមសិក្សា ដើម្បីផ្តល់ឱកាសដល់សិស្សចូលរួមច្នៃប្រឌិតសំនេរផ្សេងៗ។ ការផ្តល់ឱកាសនេះ មានបំណងដើម្បីសំដែងអោយឃើញពិតប្រាកដនូវទិដ្ឋភាពបរិស្ថានសិក្សារបស់សិស្សដើម្បីឈានទៅអភិវឌ្ឍបំណិនសរសេរអោយបានល្អប្រសើរ។ បញ្ហាទាំងនេះ រួមបញ្ចូលទាំងការខ្វះខាតគំរូសំនេរល្អ ជនគំរូល្អៗ និងវិធីក្នុងការនិពន្ធដែលផ្តោតទៅលើខ្លឹមសារជាជាង ផ្អែកទៅលើក្រិតក្រមវេយ្យាករណ៏និងអក្ខរាវិរុទ្ធនោះ។ បន្ថែមពីនេះទៀត សាលារៀនភាគច្រើនផ្តេកផ្តួលទៅលើតែវត្ថុបំណងរបៀបប្រលង ដែលរឹតត្បិតឱកាសសម្រាប់សេរីភាពក្នុងការនិពន្ធ។ យើងជឿជាក់ថា ស្ថានភាពអប់រំក្នុងសាលារៀនបែបនេះបានធ្វើអោយសិស្សមិនយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍបំណិនសរសេរផ្សេងទៀតដែលមាន។ ការរៀបចំក្លឹបនិពន្ធ ត្រូវបានគេមើលឃើញថា ជាវិធីមួយជួយសិស្សអោយមានការអភិវឌ្ឍបំណិនសរសេរផ្សេងៗដែលគេមាន។ ដោយយោងទៅលើបញ្ហានេះ ក្លិបនិពន្ធនឹងអាចជំរុញទឹកចិត្តសិស្សសរសេរ ដោយដាក់ចេញនូវលំនាំសរសេរបែបវិជ្ជមាន។ សមាជិកក្លិប ត្រូវបានលើកទឹកចិត្តនិងជួយ ក្នុងការពិភាក្សាសំនេររបស់ពួកគេបែបស្ថាបនា ដែលមានលក្ខណៈផ្ទុយទៅនឹងរបៀបវាយតម្លៃធម្មតាដែលគេជួបប្រទះក្នុងថ្នាក់។ ព័ត៌មានត្រលប់នឹងត្រូវបានផ្តល់អោយ ទាំងមិត្តរួមថ្នាក់និងគ្រូដឹកនាំ ដើម្បីឈានទៅរកការវាយតម្លៃផ្ទាល់ខ្លួន។ ក្លិបនឹងគាំទ្រសកម្មភាពផ្សេងៗ ដែលជួយផ្តល់តម្លៃសំនេររបស់សិស្ស រួមមាន ការបោះពុម្ពផ្សាយស្នាដៃសំនេររបស់សិស្ស ពិធីប្រលងប្រណាំង និងការបញ្ជូនស្នាដៃទៅបោះពុម្ពផ្សាយតាមកាសែត ទស្សនាវដ្តីក្នុង ស្រុក។ ជាចុងក្រោយ ក្លិបនឹងរកអោយឃើញ និងផ្តល់ជូនបន្ថែមទៀត ក្នុងការលើកទឹកចិត្តសិស្ស ដូចជាបង្រៀនសិស្សអោយយល់ពីរបៀបសរសេររឿងប្រលោមលោកបច្ចុប្បន្ន អំណាននិងពិភាក្សាជាមួយមិត្តរួមសាលា និងឱកាសជួបជាមួយអ្នកនិពន្ធល្បីៗក្នុងប្រទេសកម្ពុជា។ យើង សង្ឃឹមថា ឱកាសសិក្សាបន្ថែមនេះនឹងជួយបង្កើនចំណាប់អារម្មណ៍រៀនសូត្របន្ថែមទៀត ក្នុងការឆ្លើយតបទៅនឹងទស្សនៈសាលាកុមារមេត្រី។

## ២. វត្ថុបំណង

ដោយផ្អែកលើការពិភាក្សាចំពោះបញ្ហាពាក់ព័ន្ធ ក្នុងការជួយសិស្សអោយចេះសរសេរនោះ សកម្មភាពក្លិបនិពន្ធមានវត្ថុបំណងដូចខាងក្រោម :

- សិស្សមានឱកាសអភិវឌ្ឍបំណិនសរសេរដោយស្ថាបនា មិនមានការបង្ខិតបង្ខំ ស្ថិតក្នុងបរិស្ថាន លើកទឹកចិត្ត
- សិស្សត្រូវបានលើលទឹកចិត្តក្នុងការសរសេរ ច្រើនជាងអ្វីដែលគេធ្លាប់រៀនបច្ចុប្បន្នក្នុងថ្នាក់រៀន
- គ្រូបង្រៀនអាចប្រើមេរៀននេះ ក្នុងការជួយសិស្សអោយចេះរៀបចំរចនាសម្ព័ន្ធសកម្មភាពផ្សេងៗ ដែលតម្រូវអោយពួកគេអភិវឌ្ឍបំណិនផ្ទាល់ខ្លួនរបស់គេ ។

## ៣. លទ្ធផល

ដើម្បីសំរេចបានដូចវត្ថុបំណងខាងលើនេះ ត្រូវពឹងផ្អែកលើលទ្ធផលរបស់សកម្មភាពទាំងឡាយ ដូច ខាងក្រោម :

-រៀបចំយន្តការដែលនឹងតម្រូវអោយសិស្សពង្រឹងសមត្ថភាពក្នុងការសរសេរ

-បង្កើនឱកាសក្នុងការអានឯកសារក្នុងចំណោមសិស្សគោលដៅ

-ជួយសិស្សពិភាក្សាសំនេរនិងបញ្ចេញគំនិតយោបល់ ដើម្បីឈានទៅបង្កើនចំណេះដឹងផ្ទាល់ខ្លួន ។

## ៤. សម្ភារ

សម្ភារដែលបង្ហាញខាងក្រោមគ្រាន់តែជាសញ្ញាណមួយ ហើយអាស្រ័យលើទំហំសកម្មភាពដែលសិស្សជ្រើសរើសមកអនុវត្ត ។

- ធនធានឯកសារ ( សំនេរដៃរឿងប្រលោមលោក គោលការណ៍និពន្ធ អត្ថបទសំរាំង ។ល ។)
- សម្ភារការិយាល័យ ប៊ិច សៀវភៅសម្រាប់សរសេរ
- ថវិកាក្លិប $130-$150 ដើម្បីសម្រួលដល់សកម្មភាពដែលបានជ្រើសរើស (ដំណើរទស្សនៈកិច្ចសិស្ស ថតចម្លងអត្ថបទសំនេរសិស្ស ថវិកាវាគ្មិនកិត្តិយស ។ល ។)
- ប្រាក់ឧបត្ថម្ភគ្រូដឹកនាំ ( បង្រៀនសិស្ស ៣០០០រៀល/ម៉ោង និងជូនសិស្សទស្សនៈកិច្ច ១០០០០រៀល/ថ្ងៃ) ។

## ៥. លំនាំនៃការអនុវត្តសកម្មភាព

### ៥.១ គោលការណ៍រៀបចំក្លឹប

ការបង្កើតក្លឹបនិពន្ធត្រូវធ្វើឡើងដោយមានគោលការណ៍គ្រប់គ្រងសំខាន់ៗមួយចំនួន។ គាលការណ៍ទាំង នោះគឺៈ

**ការស្ម័គ្រចិត្ត :**

ការចូលរួមក្នុងក្លិបនេះ គឺមិនមែនសំរាប់មនុស្សគ្រប់គ្នាទេ ហើយអ្នកសម្របសម្រួលតាមសាលាត្រូវយល់ថា មិនគួរមានការបង្ខិតបង្ខំសិស្សឱ្យចូលរួមក្នុងក្លិបនេះទេ ព្រោះសិស្សអាចមានចំណូលចិត្តខុសៗគ្នា ហើយអ្នកសម្របសម្រួលគួរជួយឧបត្ថម្ភដល់សិស្សទាំងនោះឱ្យបានសមរម្យ។ ឧទាហរណ៏ គេអាចបង្កើតក្លិបទាំងនេះនៅក្នុងពេលតែមួយបាន មានន័យថាប្រហែលជាមានគ្រូផ្សេងៗទៀតកំពុងបង្កើតក្លិបមុខវិជ្ជាដទៃទៀតក្នុងពេលនោះដែរ ដូចជាមុខវិជ្ជាវិទ្យាសាស្ត្រ កីឡាជាដើម។ យើងត្រូវផ្តល់ពេលឱ្យសិស្សជ្រើសរើសមុខវិជ្ជាដែលពួកគេចង់រៀនឱ្យបានកាន់តែទូលាយ និងត្រូវមើលថាតើពួកគេមានពេលវេលា និងចំណូលចិត្តក្នុងការចូលរួមក្លិបឬទេ ។

ដូចគ្នានេះដែរ គ្រូក៏ពុំមានការបង្ខំឱ្យរៀបចំក្លិបនិពន្ធនេះដែរ។ <u>សេចក្តីត្រេកអរ និងការចាប់អារម្មណ៏របស់គ្រូចំពោះមុខវិជ្ជានិពន្ធ</u> ជាប្រការចាំបាច់ណាស់ក្នុងការឈានទៅដល់ភាពជោគជ័យរបស់ក្លិប ហើយយើងគួរគិតថា សេចក្តីត្រេកអរនោះបានពីមានការបង្ខំគ្រូឱ្យធ្វើសកម្មភាពឬមួយយ៉ាងណា។ ព្រមជាមួយគ្នានេះដែរ គ្រូស្ម័គ្រចិត្តអាចចំណាយពេលផ្ទាល់ខ្លួនរបស់គេខ្លះ ដើម្បីធ្វើផែនការសកម្មភាពជាមួយសិស្ស ដូចជាការចូលរួមប្រជុំក្រៅម៉ោងសាលារដ្ឋ និងការធ្វើដំណើរទៅតាមកន្លែងសិក្សានានា។ អ្នកកាន់កម្មវិធីត្រូវពិចារណាលើទម្រង់ការមួយចំនួនទាក់ទងទៅនឹងប្រាក់ឧបត្ថម្ភគ្រូបង្រៀន ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងទម្រង់ថវិកានៃសកម្មភាពផ្សេងទៀត ដូចជា កម្មវិធីបំណិនជីវិត គេហកិច្ចជាដើម (៣.000រៀល/ម៉ោង) ។

**ថ្នាក់គោលដៅ :**

ការចូលរួមក្នុងក្លិបនិពន្ធ គឺជាសកម្មភាពមួយដែលគួរតែមានមានសិស្សកំរិតដូចគ្នា មិនគួរមានសិស្សចំរុះគ្នាច្រើនពេលនោះទ។ នៅពេលសាលារៀនមានបទពិសោធច្រើនហើយនោះ គ្រូណែនាំអាចបង្កើតក្លិបច្រើនបានតាមកំរិតថ្នាក់ទី ៧ ទី៨ រឺទី៩។

**<u>ការស្ទាបស្ទង់ចំណូលចិត្តរបស់សិស្ស និងការប្រើប្រាស់ឧត្តតំរង់ទិស:</u>**

ការសម្រេចចិត្តរបស់សិស្សក្នុងការចូលរួមក្លិប គឺអាស្រ័យលើការសម្រេចចិត្តជាមុនរបស់ពួកគេ ។ ក្នុងការស្ទាបស្ទង់ចំណាប់អារម្មណ៍របស់សិស្សអំពីការចូលរួមក្លិបនេះ គ្រូត្រូវពន្យល់ណែនាំអំពីអត្ថន័យនៃ ក្លិបនោះ។ ការណែនាំនេះអាចនិយាយផ្ទាល់មាត់ទៅកាន់សិស្សក្នុងថ្នាក់ ឬអាចសរសេរបិទនៅតាមទី សារធារណៈ ឬយើងអាចប្រើវិធីទាំងពីរនេះតែម្តង ។ សេចក្តីណែនាំទាំងអស់ត្រូវមានចំណុចខាងក្រោមនេះ :

- *វត្ថុបំនង :* ដើម្បីផ្តល់ឱកាសដល់សិស្សក្នុងការអភិវឌ្ឍបំនិនសរសេរ ។
- *សកម្មភាព :* ធ្វើដំណើរទស្សនកិច្ចសិក្សា, សំនេរទស្សនាវដ្តី ក្រុមពិភាក្សាពីអំណានប្រលោមលោក ជួបជាមួយអ្នកនិពន្ធរឿងប្រលោមលោក ចូលរួមពិធីប្រលងប្រណាំងសំនេរ ។ល។
- *ការវាយតម្លៃ :* ពុំមានការវាយតម្លៃ ឬដាក់ពិន្ទុជាលក្ខណៈផ្លូវការទេ គឺសិស្សត្រូវបានគេឱ្យចូលរួមក្នុងសកម្មភាព ពីព្រោះពួកគេចង់ធ្វើ ពុំមែនដោយសារតែគេបង្ខំឡើយ ។
- *ការចូលរួម :* សមាសភាពក្លិបចូលរួមដោយស្ម័គ្រចិត្ត ។
- *ការប្រជុំ :* មានការប្រជុំសាមញ្ញ (ប្រហែលជា២សប្តាហ៍ម្តង) ដើម្បីពិភាក្សាអំពីសកម្មភាពដែលបានគ្រោងទុក ។

ចំណុចខាងលើនេះនឹងត្រូវបានគេអនុវត្តបន្ទាប់ពីម៉ោងបង្រៀនឬនៅថ្ងៃណាដែលសាលាទំនេរ ។ ដោយអនុវត្តតាមសេចក្តីណែនាំនេះ យើងត្រូវសួរសិស្សថា តើពួកគេចាប់អារម្មណ៍ក្នុងការចូលរួមក្លិបនេះឬទេ ហើយកំណត់ឱ្យបានពីកម្រិតនៃការចាប់អារម្មណ៍របស់ពួកគេ ។ ក្នុងការស្ទាបស្ទង់ចំណាប់អារម្មណ៍របស់សិស្ស យើងប្រើទម្រង់ដែលមាននៅក្នុង<u>ឯកសារយោងទី១</u>។ ទម្រង់នេះមានប្រយោជន៍ ពីព្រោះវាទប់ស្កាត់សិស្ស មិនឱ្យមានការគាបសង្កត់ និងបង្ខំឱ្យនិយាយថា **យល់ព្រម** ឬ **មិនយល់ព្រម** ជាពិសេសនៅពេលដែលគេមើលឃើញថា សិស្សបង្ហាញនូវភាពមិនស្មោះត្រង់នៅចំពោះមុខគ្រូ ។ អាស្រ័យហេតុនេះ គ្រូត្រូវផ្តល់ពេលឱ្យសិស្សរយៈពេលពី ១០ ទៅ ១៥នាទី ដើម្បីឱ្យពួកគេពិភាក្សាគ្នា និងធ្វើការសម្រេចចិត្តមុនពេលពួកគេបំពេញលើទម្រង់ និងមុនពេលដែលពួកគេយកទម្រង់នោះជូនទៅគ្រូវិញ ។

**<u>ការបែងចែកភារកិច្ច</u> :**

នៅពេលមានកិច្ចប្រជុំក្លិបជាលើកដំបូងគ្រូដែលមានភារកិច្ចទទួលខុសត្រូវក្លិបត្រូវសុំឱ្យមានការជ្រើសរើសសមាជិកមួយចំនួនដើម្បីឱ្យទទួលខុសត្រូវលើបញ្ហាមួយចំនួន។ ការជ្រើសរើសនេះអាចនឹងធ្វើឡើងដោយការបោះឆ្នោតឬតាមរយៈការស្រែកលើកដៃ។ តួនាទីគឺមិនទៀងទាត់ទេវាអាចជា ១.**ប្រធានក្លិប** ២.**អនុប្រធាន** និង ៣.**លេខាធិការ** ។ ប្រសិនបើមានសិស្សច្រើននាក់នៅក្នុងក្លិប (ឧ.១៥ នាក់ ឬច្រើនជាងនេះ) ចាំបាច់

ត្រូវមានប្រធានក្រុម ១នាក់ សម្រាប់គ្រប់គ្រងលើសិស្ស ៤ ឬ ៥នាក់ ។ ចំពោះភារកិច្ចទទួលខុសត្រូវដែលបានលើកឡើងនេះ សូមមើល នៅក្នុង<u>**ឯកសារយោងទី២**</u> ហើយត្រូវបង្ហាញដល់សមាជិកក្លឹបទាំងអស់ និងធ្វើការពន្យល់ដល់គ្រូទាំងអស់ ។ ក្នុងជំហានដំបូងនៃសកម្មភាពក្លឹប គ្រូដែលមានភារកិច្ចទទួលខុសត្រូវលើការងារនេះ ត្រូវមានទំនាក់ទំនងល្អក្នុងការចូលរួមចំណែកជួយដល់សមាជិកក្លឹប ដើម្បីបំពេញតួនាទីរបស់ពួកគេ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គ្រូរូបនោះត្រូវខិតខំប្រឹងប្រែងលើភារកិច្ចរបស់ខ្លួនឱ្យបានខ្លាំងក្លាដើម្បីជួយសិស្សធ្វើអោយបទពិសោធន៍របស់គេបានល្អប្រសើរឡើង ។

<u>**ការធ្វើផែនការ**</u> :

កិច្ចការមួយក្នុងចំណោមកិច្ចការទាំងឡាយដែលក្លិបត្រូវធ្វើនោះគឺ ការធ្វើផែនការលើសកម្មភាពដែលបានស្នើសុំធ្វើក្នុងរយៈពេល១ត្រីមាស១។ ទម្រង់ផែនការដែលជួយឱ្យក្លិបធ្វើសកម្មភាព ដែលមានលក្ខណៈសមស្រប ពីមួយសប្តាហ៍ ទៅមួយសប្តាហ៍នៅក្នុង ខែនីមួយៗ ***គឺមានបង្ហាញនៅក្នុង<u>ឯកសារយោងទី</u> ៣***។ មុនពេលធ្វើផែនការ គ្រូគួរតែព្យាយាម ពិនិត្យមើលថាតើសកម្មភាពណាដែលអាចធ្វើទៅបាន ហើយកំណត់យកគំរោង២ ឬ៣ ដែលក្លិបនឹងអនុវត្ត នៅក្នុងត្រីមាសនីមួយៗ ។ ឧទាហរណ៍ ក្លិបចង់ឱ្យសិស្សសិក្សាអំពីប្រាសាទនៅក្នុងតំបន់មួយ។ មុនពេលទៅមើលប្រាសាទនោះ គ្រូអាចបរិយាយអំពីប្រវត្តិខ្លះៗនៃប្រាសាទនោះ និងណែនាំពីអ្វីដែលត្រូវឱ្យសិស្សធ្វើនៅពេលទៅដល់ រួមមាន ការមើល ថាតើប្រាសាទនោះត្រូវបានកសាងនៅឆ្នាំណា (ដោយពិនិត្យមើលបែបបទ នៃអក្សរសិលាចារិក) ទីតាំង និង រចនាបទ ប្រាសាទ ការថតរូបក្បាច់ចំលាក់សំខាន់ៗ ការផ្តិតអក្សរសិលាចារិក និងការអានអំពីប្រវត្តិរបស់ប្រាសាទនោះជាមុន ។ គ្រូអាចពន្យល់សិស្សអំពីរបៀបនៃការពិនិត្យមើលវត្ថុទាំងនោះផងដែរ។ *សូមមើល<u>ឯកសារយោងទី៤</u>*។ នៅពេលការសិក្សា ស្រាវជ្រាវនេះបានបញ្ចប់ ក្លិបត្រូវរៀបចំការដាក់តាំងពិពណ៌នៅក្នុងបណ្ណាល័យ ឬថ្នាក់រៀនព្រមទាំងធ្វើការរៀបរាប់អំពីអ្វី ដែលបានស្រាវជ្រាវនោះទៅដល់ សិស្សដទៃទៀតដែលមិនមែន ជាសមាជិករបស់ក្លិប។ គ្រប់សកម្មភាពទាំងនេះ គួរតែសរសេរទុកនៅក្នុងផែនការ ។ សូមមើលឧទាហរណ៍នៅក្នុងតារាងខាងក្រោម :

| សកម្មភាព | វិច្ឆិកា | | | | ធ្នូ | | | | មករា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១.កិច្ចប្រជុំទី១: ស្វែងរកគំរោងស្រាវជ្រាវប្រវត្តិសាស្ត្រ ។ | X | | | | | | | | | | | |
| ២.កិច្ចប្រជុំទី២: ការសិក្សាស្រាវជ្រាវលើកដំបូង ។ (ការរៀនពីអក្សរខ្មែរបុរាណ) | | X | | | | | | | | | | |
| ៣.កិច្ចប្រជុំទី៣: ការសិក្សាស្រាវជ្រាវលើកដំបូង ។ (ការរៀនពីរចនាបទប្រាសាទ, ទីតាំង ។ល ។) | | | | X | | | | | | | | |
| ៤.ដំណើរទស្សនកិច្ចលើកដំបូងទៅកាន់ប្រាសាទបុរាណក្នុងតំបន់ | | | | X | | | | | | | | |
| ៥.ដំណើរទស្សនកិច្ចលើកទី២ទៅកាន់ប្រាសាទបុរាណ ក្នុងតំបន់ | | | | | X | | | | | | | |
| ៦.កិច្ចប្រជុំទី៤: រៀបចំផែនការតាំងពិពណ៌ ដើម្បីឱ្យដឹងថាតើដំណើការនៃការស្រាវជ្រាវនោះយ៉ាងដូចម្តេច ។ រៀបចំកិច្ចការ ហើយត្រូវសម្រេចចិត្តថាតើនរណាត្រូវធ្វើកិច្ចការនោះ ។ | | | | | | X | | | | | | |
| ៧.ជួបជុំគ្នាដើម្បីរៀបចំការតាំងពិពណ៌នៅក្នុងបណ្ណាល័យ | | | | | | | X | X | | | | |
| ៨.ធ្វើឧទេសនាមអំពីប្រាសាទដល់សិស្សដទៃទៀត ។ | | | | | | | | | X | | | |

**ធនធាន** :

ដើម្បីធ្វើឱ្យសកម្មភាពក្លិបប្រកបដោយប្រសិទ្ធិភាព វាចាំបាច់ត្រូវមានធនធាន រួមមាន សមត្ថភាព/សម្បទានទាំងឡាយ ដូចជា កន្លែងប្រជុំ (បណ្ណាល័យ ឬថ្នាក់រៀនទំនេរ) សៀវភៅបណ្ណាល័យ សម្រាប់ការសិក្សាស្រាវជ្រាវ, បន្ទប់កុំព្យូទ័រមានដំណើរការ សម្រាប់សរសេររបាយការណ៍ (ចំពោះថ្នាក់ មធ្យមសិក្សាក៏រិត១) ឬធនធានថវិកា ។ ធនធានថវិកាជាតម្រូវការសម្រាប់អនុវត្តសកម្មភាពជាក់ស្តែង ដូចខាងក្រោម :

- ក្រដាសសម្រាប់កត់ត្រា ឬសរសេររបាយការណ៍ (សម្រាប់ក្រុមទាំងអស់)
- ក្រដាសផ្ទាំងធំសម្រាប់គូផែនទី, ធ្វើការដាក់តាំងពិពណ៌, ប្រជុំ
- ហ្វីតសម្រាប់តាំងពិពណ៌
- ថវិកាធ្វើដំណើរចុះកម្មសិក្សាស្រាវជ្រាវ
- ម៉ាស៊ីនថតរូបដែលប្រើហើយបោះចោល(ប្រើបានតែម្តង)
- ថវិកាសម្រាប់ចំណាយផ្សេងៗ

គណៈកម្មការត្រូវធ្វើផែនការបែងចែកថវិកា ដែលចាត់ទុកជាដំណើការនៃការរៀបចំផែនការប្រចាំឆ្នាំនៅរៀងរាល់ដើមឆ្នាំសិក្សា ។ *សូមមើលឯកសារយោងទី ៤* ។

## ៥.២ សកម្មភាពដែលត្រូវអនុវត្ត

១. បង្កើតសិក្ខាសាលាស្តីពីការតែងនិពន្ធ :

-លំហាត់កសាងសមត្ថភាពចម្បងរបស់សិស្ស រយៈពេល១-២ថ្ងៃ ដោយផ្តោតទៅលើយន្តការនិពន្ធ តម្រូវការធនធានមនុស្សពីខាងក្រៅ ។

២. ការប្រជុំវាយតម្លៃស្តីពីអំណាន : សិស្សមានឱកាសជួបប្រជុំគ្នា ដើម្បីពិភាក្សាទៅលើសៀវភៅសំនេរមួយ ក្នុងការផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមក ។ សិស្សជួបប្រជុំគ្នាផ្លាស់ប្តូរអំពីសំនេរទៅវិញទៅមក ។ ទីកន្លែងប្រជុំគួរតែមានសមស្រប មានអនាម័យ និងខ្យល់អាកាសល្អ ។

៣. ភ្ញៀវជាវាគ្មិន : អញ្ជើញអ្នកនិទ្ទល្បីល្បាញពីភ្នំពេញ ដើម្បីទស្សនៈកិច្ចក្លិប និងបង្ហាញបទឧទ្ទេសនាមពីបទពិសោធ និងស្នាដៃនិពន្ធសៀវភៅថ្មីៗបំផុតរបស់គាត់ ។ សិស្សមានឱកាសសួរសំណួរទោលើវាគ្មិននោះ ។ ការឧទ្ទេសនាមគួរតែរៀបចំមានលក្ខណៈមិនផ្លូវការ ដែលលើកទឹកចិត្តអោមានការសន្ទនាស្និតស្នាលទៅវិញទៅមក ។

៤. បោះពុម្ពផ្សាយស្នាដៃរឿងខ្លីៗរបស់ក្លិប : នៅចុងឆ្នាំសិក្សា រឿងនិពន្ធល្អៗរបស់សិស្សនឹងត្រូវចងក្រងជាសៀវភៅ ហើយថតចម្លងទុកអោយសមីខ្លួនមួយក្បាលៗ និងមួយចំនួនទៀតដាក់តាំងក្នុងបណ្ណាល័យសាលារៀន ។ សិស្សជ្រើសរើសរឿងនិពន្ធផ្ទាល់ខ្លួនសម្រាប់បោះពុម្ពដាក់ជូនគ្រូពិនិត្យ ។

៥. ការឆ្លុះបញ្ចាំងពីដំនើរទស្សនៈកិច្ច : សិស្សធ្វើទស្សនៈកិច្ចទៅកាន់កន្លែងគួរអោយចាប់អារម្មណ៏ដែលជាវិធីមួយជំរុញទឹកចិត្តសិស្សអោយមានសំនេរច្នៃប្រឌិត (ឧ. ប្រាសាទបុរាណ កន្លែងទឹក ធ្លាក់ ព្រៃភ្នំ ឆ្នេរសមុទ្រ ។ល ។) សិស្សសរសេរពិបទពិសោធក្នុងជីវិតដែលគេជួបប្រទះ

៦. **ទិនានុប្បវត្តសិស្ស :** សិស្សរក្សាទិនានុប្បវត្តអំពីជីវិតផ្ទាល់ខ្លួន បទពិសោធគួរអោយចាប់ អារម្មណ៏ ការទំនាក់ទំនងគ្នាក្នុងសង្គម ជីវិតគ្រួសារ ។ល ។ ក្លិបនឹងផ្តល់នូវសៀវភៅតូចៗដល់ សិស្ស ដើម្បីរក្សាទិនានុប្បវត្តរបស់ខ្លួន

៧. **ទំនាក់ទំនងជាមួយកន្លែងបោះពុម្ពផ្សាយនៅក្នុងស្រុក ដើម្បីបោះពុម្ពផ្សាយស្នាដៃនិពន្ធរបស់ សិស្ស ។ ប្រើកុំព្យូទ័រក្នុងការវាយឯកសារទាំងនេះ ។**

៨. **ការប្រកួតប្រជែងសំនេរនិពន្ធ :** បង្កើតគណៈកម្មការវាយតម្លៃ រឿងនិពន្ធខ្លីៗរបស់សិស្សក្នុង ក្លិបតាមសាលាផ្សេងៗទៀត ។ ផ្តល់រង្វាន់លើកទឹកចិត្តស្នាដៃនិពន្ធដែលល្អ ។

**៩. ការប្រជុំវាយតម្លៃស្តីពីដំណើរការប្រចាំឆ្នាំរបស់ក្លិបតាមសាលានីមួយៗ**

សូមយកទម្រង់ ដំណើរទស្សនៈកិច្ចរបស់សាលានីមួយៗមកឆ្លុះបញ្ចាំងដោយស្តាបនា អំពីអ្វីដែលបាន កើតឡើងក្នុងដំណើរការក្លិប។ សូមយកទម្រង់កិច្ចប្រជុំ តាមសាលាដើម្បីឆ្លុះបញ្ចាំង។ សូមឈាន ទៅដល់ការវាយតម្លៃខ្លីមួយ ស្តីពីចំនុចដឹកនាំត្រូវកែលំអនៅឆ្នាំខាងមុខរបស់ក្លិបនីមួយៗ។

១០. ព្រឹត្តិបត្រសាលារៀន :

ក្លិបត្រូវរៀបចំការបោះពុម្ពផ្សាយខ្លីមួយមានលក្ខណៈផ្ទៃក្នុង និងស្តីពីភាពរីកចំរើនរបស់សាលារៀន។ ត្រូវមានកុំព្យូទ័រសម្រាប់ធ្វើកិច្ចការនេះ។ ព្រឹត្តិបត្រផ្តល់នូវវេទិកាមួយសម្រាប់សមាជិកក្លិបផ្សព្វ ផ្សាយអោយបានទូលាយនូវស្នាដៃនិពន្ធរបស់គេម្នាក់ៗប្រចាំឆ្នាំ។

**ឯកសារយោងទី ១ :** **ការសំរេចចិត្តរបស់សិស្ស**

**ឈ្មោះ ...................... ថ្នាក់ទី ....... កាលបរិច្ឆេទ ..........**

**សេចក្តីផ្តើម**

ការចូលរួមក្លិបនិពន្ធគឺជាឱកាសមួយដើម្បីអនុវត្តសកម្មភាពគួរឱ្យចាប់អារម្មណ៍ដែលជួយយើងអភិវឌ្ឍថាមពលក្នុងការបញ្ចេញមតិទាំងផ្ទាល់មាត់ និងសំនេរ។ ហើយនេះគឺជាចំណុចមួយចំនួនដែលអ្នកគួរដឹង មុនពេលដែលអ្នកសម្រេចចិត្តថាតើត្រូវចូលរួមក្លិប ឬមួយយ៉ាងណា :

- *វត្ថុបំនង :* ដើម្បីផ្តល់ឱកាសដល់សិស្សក្នុងការអភិវឌ្ឍបំនិនសរសេរ ។
- *សកម្មភាព :* ធ្វើដំណើរទស្សនកិច្ចសិក្សា, សំនេរទស្សនាវដ្តី ក្រុមពិភាក្សាពីអំណានប្រលោមលោក ជួបជាមួយអ្នកនិពន្ធរឿងប្រលោមលោក ចូលរួមពិធីប្រលងប្រណាំងសំនេរ ។ល។
- *ការវាយតម្លៃ :* ពុំមានការវាយតម្លៃ ឬដាក់ពិន្ទុជាលក្ខណៈផ្លូវការទេ គឺសិស្សត្រូវបានគេឱ្យចូលរួមក្នុងសកម្មភាព ពីព្រោះពួកគេចង់ធ្វើ ពុំមែនដោយសារតែគេបង្ខំឡើយ ។
- *ការចូលរួម :* សមាសភាពក្លិបចូលរួមដោយស្ម័គ្រចិត្ត ។
- *ការប្រជុំ :* មានការប្រជុំសាមញ្ញ (ប្រហែលជា២សប្តាហ៍ម្តង) ដើម្បីពិភាក្សាអំពីសកម្មភាពដែលបានគ្រោងទុក ។

***ចំណុចខាងលើនេះនឹងត្រូវបានគេអនុវត្តបន្ទាប់ពីម៉ោងបង្រៀនឬនៅថ្ងៃណាដែលសាលាទំនេរ ។***

**តារាងសំណួរ** (Questionnaire)

សូមបង្ហាញអំពីកម្រិតនៃការចាប់អារម្មណ៍របស់អ្នកអំពីការចូលរួមក្នុងក្លិបនិពន្ធ ដោយរើសយកប្រអប់តែមួយក្នុងចំណោមប្រអប់ទាំង៣ ខាងក្រោមនេះ :

☐ ខ្ញុំគ្មានចំណាប់អារម្មណ៍សោះក្នុងការចូលរួមក្នុងក្លិបនិពន្ធនេះ ។

☐ ខ្ញុំប្រហែលជាចាប់អារម្មណ៍ក្នុងការចូលរួមក្លិបនេះ
ប៉ុន្តែខ្ញុំមិនដឹងច្បាស់ថាតើខ្ញុំអាចមានពេលនឹងចូលរួមដែរឬទេ ។

☐ ខ្ញុំចាប់អារម្មណ៍ក្នុងការចូលរួមក្លិបនេះណាស់ ហើយខ្ញុំដឹងច្បាស់ថាខ្ញុំមានពេលដើម្បីចូលរួមក្លិបនេះ ។

ហត្ថលេខាសិស្ស

## ឯកសារយោងទី ២ : ភារកិច្ចរបស់ប្រធានក្លិបដែលបានជ្រើសរើស

### ❶ ប្រធានអង្គក្លិប

- រៀបចំការប្រជុំក្លិប
- សម្របសម្រួលការរៀបចំរបៀបវារៈនៃកិច្ចប្រជុំនីមួយៗ
- សម្របសម្រួលការប្រជុំ
- ធានាថាមានន្លែងសម្រាប់ប្រជុំ បន្ទាប់ពីបានសម្របសម្រួលជាមួយនាយកសាលា
- បង្កើតសម្ព័ន្ធភាពរវាងក្លិប និងគណៈកម្មការកម្រងសាលា
- ត្រួតពិនិត្យការអនុវត្តផែនការប្រចាំត្រីមាស
- រាយការណ៍អំពីបញ្ហាទាំងឡាយដែលបានកើតឡើងដល់គ្រូដែលទទួលខុសត្រូវក្លិប

### ❷ អនុប្រធានក្លិប

- បំពេញតួនាទីជាប្រធានអង្គប្រជុំ នៅពេលដែលប្រធានអវត្តមាន
- ជួយសម្របសម្រួលកិច្ចប្រជុំ
- កត់ត្រាកំណត់ហេតុ

### ❸ ហេរញ្ញិក

- ទទួលខុសត្រូវលើថវិកាដែលគ្រូទទួលខុសត្រូវក្លិបផ្តល់ឱ្យ ចំពោះសកម្មភាពផ្សេងៗ រួមមានការទិញសម្ភារៈសម្រាប់ការតាំងពិពណ៌ ការធ្វើដំណើរស្រាវជ្រាវ ។ល។
- ថែរក្សាកំណត់ត្រាថវិកាទាំងអស់ដែលទទួលបានពីគ្រូដែលទទួលខុសត្រូវក្លិប
- ទិញ ឬចំណាយតាមការបង្គាញរបស់គ្រូទទួលខុសត្រូវក្លិប

### ❹ ប្រធានក្រុម

- ទទួលខុសត្រូវលើការដឹកនាំក្រុម
- ធ្វើរបាយការណ៍តំណាងក្រុមជូនដល់ប្រធានអង្គប្រជុំ ឬគ្រូទទួលខុសត្រូវក្លិប
- ផ្សព្វផ្សាយព័ត៌មានដែលទទួលបានពីប្រធានអង្គប្រជុំ ឬ គ្រូទទួលខុសត្រូវក្លិបដល់សមាជិកក្នុងក្រុម ។

## គ្រូទទួលខុសត្រូវក្លិប

- ផ្ដល់ការណែនាំដល់ក្លិបក្នុងការបង្កើតផែនការ រៀបចំការប្រជុំជ្រើសរើសប្រធានក្លិបដើម្បីឱ្យគាត់អាចធ្វើការងារផ្សេងៗបានដោយខ្លួនឯង ។
- ជួយផ្នែកបច្ចេកទេសនូវរាល់បញ្ហាដែលទាក់ទងនឹងប្រវត្តិសាស្ត្រ ( មេរៀនស្ដីអំពីអក្សរបុរាណ យុគសម័យប្រវត្តិសាស្ត្រនៅក្នុងប្រទេសកម្ពុជា ។ល។
- តំណាងក្លិបចំពោះគណៈកម្មការកម្រង នៅពេលធ្វើប្រតិបត្តិការណ៍ថវិកា
- សម្របសម្រួលសកម្មភាពផ្សេងៗដូចជា ការរៀបចំផែនការ និងការធ្វើដំណើរស្រាវជ្រាវ
- សម្របសម្រួលផ្នែកទំនាក់ទំនងរវាងក្លិប និងរដ្ឋបាលរបស់សាលារៀននៅពេលមានសកម្មភាពផ្សេងៗគ្នា

ដូចជា

ការប្រើប្រាស់បណ្ណាល័យសម្រាប់ប្រជុំ ជាដើម ។

- ត្រួតពិនិត្យធនធានថវិកាដែលក្លិបប្រើប្រាស់។

## ឯកសារយោងទី ៣ : ផែនការរបស់ក្លឹបនិពន្ធ

### ត្រីមាសទី ១:

| សកម្មភាព | | ធ្នូ | | | | មករា | | | | កុម្ភៈ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១ | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | |
| ៥ | | | | | | | | | | | | | |
| ៦ | | | | | | | | | | | | | |
| ៧ | | | | | | | | | | | | | |
| ៨ | | | | | | | | | | | | | |
| ៩ | | | | | | | | | | | | | |
| ១០ | | | | | | | | | | | | | |
| ១១ | | | | | | | | | | | | | |
| ១២ | | | | | | | | | | | | | |
| ១៣ | | | | | | | | | | | | | |
| ១៤ | | | | | | | | | | | | | |
| ១៥ | | | | | | | | | | | | | |

### ត្រីមាសទី ២:

| សកម្មភាព | | មីនា | | | | ឧសភា | | | | មិថុនា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១ | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | |
| ៥ | | | | | | | | | | | | | |
| ៦ | | | | | | | | | | | | | |
| ៧ | | | | | | | | | | | | | |
| ៨ | | | | | | | | | | | | | |
| ៩ | | | | | | | | | | | | | |
| ១០ | | | | | | | | | | | | | |
| ១១ | | | | | | | | | | | | | |
| ១២ | | | | | | | | | | | | | |
| ១៣ | | | | | | | | | | | | | |
| ១៤ | | | | | | | | | | | | | |
| ១៥ | | | | | | | | | | | | | |
| | | | | | | | | | | | | | |

## ឯកសារយោងទី ៤ : ការបកស្រាយអំពីថវិកាសម្រាប់ក្លិបនិពន្ធ

| ចំណាយ | រូបមន្ត | ចំនួន |
|---|---|---|
| ១. ក្រដាសធំ (Poster paper) | 1kg x $2 / kg | $2.00 |
| ២. ហ្វឺត | 2ប្រអប់ x $2.50 / ប្រអប់ | $5.00 |
| ៣. ក្រដាសពណ៌ | 2ដុំ x $4 / ដុំ | $8.00 |
| ៤. ការតាំងពិពណ៌ប្រវត្តិសាស្ត្រនៅបណ្ណាល័យ | | $10.00 |
| ៥. ដំណើរស្រាវជ្រាវលើកទី 1 | | |
| អាហារថ្ងៃត្រង់:<br>ថ្លៃរថយន្តឈ្នួល:<br>ម៉ាស៊ីនថតដែលប្រើហើយបោះចោល: | 15នាក់ x $1<br>$25 x 1ថ្ងៃ<br>ម៉ាស៊ីនថត 1 x $8 | $15.00<br>$25.00<br>$8.00 |
| សរុប | | $48.00 |
| ៦. ដំណើរស្រាវជ្រាវលើកទី 2 | | |
| អាហារថ្ងៃត្រង់:<br>ថ្លៃរថយន្តឈ្នួល:<br>ម៉ាស៊ីនថតដែលប្រើហើយបោះចោល: | 15នាក់ x $1<br>$25 x 1ថ្ងៃ<br>ម៉ាស៊ីនថត 1 x $8 | $15.00<br>$25.00<br>$8.00 |
| សរុប | | $48.00 |
| **សរុប** | | **$121.00** |